# សេចក្តីណែនាំទូទៅ សម្រាប់ការធ្វើតេស្តជំនាញ

សូមអានសេចក្តីណែនាំទាំងនេះ ខណៈដែលអ្នកកំពុងរង់ចាំធ្វើតេស្តជំនាញ។
កាតនេះ ត្រូវតែ បញ្ជូនត្រលប់ទៅអ្នកវាយតម្លៃដែលជាអ្នកផ្តល់តេស្ត ឲ្យអ្នក។

**នៅពេលអ្នកត្រូវបានហៅចូលទៅក្នុងបន្ទប់ធ្វើតេស្ត អ្នកវាយតម្លៃនឹង:**

- ស្នើសុំមើលអត្តសញ្ញាណរបស់អ្នក។
- បង្ហាញបន្ទប់ដល់អ្នក ដូច្នេះអ្នកអាចមើលការផ្គត់ផ្គង់ និងបរិក្ខារដែលចាំបាច់សម្រាប់ធ្វើតេស្ត។

សម្រាប់ ការធ្វើតេស្តជំនាញ អ្នក នឹងបង្ហាញ ជំនាញ ចំនួនបី ដែលអ្នកអាចធ្វើនៅពេលថែទាំអតិថិជន។ នៅពេលអ្នកធ្វើការបង្ហាញជំនាញទាំងនេះ អ្នកវាយតម្លៃនឹងធ្វើការអង្កេត និងកត់ត្រាការបង្ហាញរបស់អ្នក។ ជំនាញ នឹងត្រូវបានបង្ហាញដោយបេក្ខជនដើរតួជាផ្នែកមួយនៅពេលថែទាំអតិថិជន ឬជាមួយរូបតំណាង។ អ្នកគួរតែធ្វើការថែទាំ និងនិយាយទៅកាន់អ្នកសម្តែងឬរូបតំណាង ដោយទុកគេដូចជាអតិថិជនពិត។

**មុនពេលអ្នកធ្វើតេស្ត អ្នកវាយតម្លៃនឹង:**

- ផ្តល់ជូនកាតមួយដល់អ្នកដែលមានបញ្ជីជំនាញ ដែលអ្នកត្រូវបង្ហាញសម្រាប់ការធ្វើតេស្តរបស់អ្នក ដោយមានសេចក្តីណែនាំសម្រាប់ការធ្វើតេស្តនីមួយៗ។
- អានសេចក្តីណែនាំសម្រាប់ជំនាញនីមួយៗដល់អ្នក។ (អ្នកបកប្រែ នឹងជួយបើអ្នកធ្វើតេស្តមិនមែនជាភាសាអង់គ្លេស។)
- ប្រាប់អ្នកពីពេលដែលអ្នកនឹងធ្វើតេស្ត និងពេលដែលអ្នកសម្តែងដើរតួជាអតិថិជនសម្រាប់ការធ្វើតេស្តរបស់បេក្ខជនផ្សេងទៀត។

**សម្រាប់ការធ្វើតេស្តជំនាញ អតិថិជន:**

- ត្រូវបានចាត់ទុកថាដឹងជាមុន និងចូលរួមសហការ។
- អាចមានបញ្ហាកាយសម្បទារនៅក្នុងជំនាញមួយចំនួន។

**នៅពេលអតិថិជន ត្រូវបានដើរតួដោយបុគ្គលម្នាក់ (មិនមានជារូបតំណាង) បុគ្គលនោះ:**

- គឺត្រូវបានអនុញ្ញាតបានត្រឹមតែឆ្លើយសំណួររបស់អ្នកប៉ុណ្ណោះ។
- អាចផ្លាស់ទី ឬជួយក្នុងការផ្លាស់ទី។
- នឹងផ្លាស់ទី តែនៅពេលដែលសុំឲ្យផ្លាស់ទីប៉ុណ្ណោះ។

**នៅពេលអ្នកដើរតួជាអតិថិជន អ្នក:**

- គឺជាអតិថិជន ដែលដឹង និងចូលរួមសហការ និងជាអ្នកដែលអាចផ្លាស់ទី និងធ្វើតាមការណែនាំ។
- គួរផ្លាស់ទី តែនៅពេលដែលសុំឲ្យធ្វើ ដោយបេក្ខជនប៉ុណ្ណោះ។
- គួរនិយាយ តែនៅពេលដែលឆ្លើយសំណួរដែលសួរដោយបេក្ខជនប៉ុណ្ណោះ។
- អាចទទួលបានការណែនាំពិសេសពីអ្នកវាយតម្លៃអំពីតួនាទីរបស់អ្នកជាអតិថិជន។
- មិនគួរជួយបេក្ខជនផ្សេងដោយវិធីណាក៏ដោយ។ នេះរាប់បញ្ចូលទាំងការផ្តល់តម្រុយ ដោយប្រើពាក្យ សញ្ញា ឬការបង្ហាញទឹកមុខ។ អាកប្បកិរិយាប្រភេទនេះ ត្រូវបានចាត់ទុកជាការបន្លំ ហើយ បេក្ខជនទាំងពីរ នឹងត្រូវបណ្តេញចេញពីការធ្វើតេស្ត ដោយមិនផ្តល់ជូនលទ្ធផលតេស្តឡើយ។ ហេតុការណ៍នេះ នឹងត្រូវរាយការណ៍ទៅក្រសួងសុខាភិបាលរបស់រដ្ឋ Washington។

**មានពីរបីចំណុច ដែលត្រូវចងចាំ នៅពេលអ្នកធ្វើតេស្តជំនាញ។**

- អ្នកត្រូវតែបង្ហាញជំនាញពិតៗ។
- អ្នកត្រូវតែបង្ហាញពីជំនាញតាមលំដាប់ដែលបានសរសេរនៅលើកាតណែនាំ ដែលអ្នកវាយតម្លៃនឹងឲ្យទៅអ្នក។ អ្នកអាចអានកាតណែនាំសារឡើងវិញនៅគ្រប់ពេលក្នុងការធ្វើតេស្តរបស់អ្នក។

**ត្រឡប់កាតដើម្បីបន្តការអាននៅខាងខ្នង។➔**


Copyright © 2010 Prometric Inc., a Delaware corporation. All rights reserved.

- អានសេចក្តីណែនាំសម្រាប់ជំនាញនីមួយៗដោយប្រុងប្រយ័ត្ន។ សម្រាប់តេស្តនេះ អ្នកនឹងធ្វើពុតជាកំពុងធ្វើការជាមួយអតិថិជនម្នាក់លើជំនាញបី ទោះបីជាអ្នកសម្តែង អាចដើរតួជាអតិថិជនសម្រាប់ជំនាញមួយ ហើយរូបតំណាង អាចដើរតួជាអតិថិជនសម្រាប់ជំនាញផ្សេងទៀត។ ក្នុងជំនាញមួយចំនួន សេចក្តីណែនាំ ក៏នឹងផ្តល់ជូននូវព័ត៌មានជាក់លាក់អំពីសមត្ថភាព និងការអសមត្ថភាពរបស់អតិថិជនដែរ។ ឧទាហរណ៍ នៅក្នុងជំនាញស្លៀកសំលៀកបំពាក់ តួសម្តែងនឹងដើរតួជាអតិថិជនដែលមានរាងកាយខ្សោយ។ កង្វះសមត្ថភាពរាងកាយពិសេសនោះ មានតែនៅក្នុងជំនាញស្លៀកពាក់ប៉ុណ្ណោះ។ ការណែនាំពិសេសអំពីរាងកាយខ្សោយ មិនមានចំពោះអតិថិជនក្នុងជំនាញពីរផ្សេងទៀតទេ។
- ការផ្គត់ផ្គង់ និងបរិក្ខារដែលចាំបាច់ដើម្បីបង្ហាញពីជំនាញ គឺស្ថិតនៅក្នុងបន្ទប់ធ្វើតេស្ត។ បើសិនជាអ្នកមិនអាចរកឃើញរបស់អ្វីមួយ សូមសួរអ្នកវាយតម្លៃ។
- នៅពេលអ្នកបញ្ចប់ជំនាញហើយ សូមនិយាយថា ខ្ញុំរួចហើយ"។
- បើអ្នកគិតថា អ្នកបានធ្វើឲ្យមានកំហុសនៅក្នុងជំនាញ អ្នកត្រូវតែប្រាប់ដល់អ្នកវាយតម្លៃថា អ្នកនឹងត្រលប់ទៅធ្វើម្តងទៀតដើម្បីកែតម្រូវ។ អ្នក អាចធ្វើការកែតម្រូវតែលើជំនាញដែលអ្នកកំពុងបង្ហាញប៉ុណ្ណោះ។ នៅពេលអ្នកនិយាយថា អ្នករួចរាល់ជាមួយជំនាញមួយហើយ អ្នកមិនអាចត្រលប់ទៅជំនាញនោះបានឡើយ។
- នៅពេលអ្នកវាយតម្លៃ ឲ្យកាតណែនាំដល់អ្នក អ្នកនឹងត្រូវបានប្រាប់ថាអ្នកមានរយៈពេលប៉ុន្មាននាទីដើម្បីធ្វើតេស្ត។ រយៈពេល គឺអាស្រ័យលើជំនាញ។ អ្នកវាយតម្លៃ នឹងចាប់ផ្តើមរាប់ពេលវេលា នៅពេលដែលអ្នកចាប់ផ្តើមជំនាញដំបូង ហើយអ្នកនឹងត្រូវបានប្រាប់នៅពេលអ្នកនៅសល់ពេលប្រាំនាទីមុនពេលតេស្តត្រូវបញ្ចប់។
- នៅពេលអ្នកបញ្ចប់ជំនាញចុងក្រោយ សូមចាត់ទុកដូចជាអ្នកបញ្ចប់ការថែទាំអតិថិជនក្នុងថ្ងៃនោះដែរ។
- ក្នុងពេលធ្វើតេស្ត បើអ្នកវាយតម្លៃ មានការបារម្ភពីសុវត្ថិភាពធ្ងន់ធ្ងរ ការធ្វើតេស្តជំនាញនឹងត្រូវបញ្ឈប់ ហើយជំនាញនោះនឹងបញ្ចប់។
- អ្នកកំពុងធ្វើការប្រឡងថ្នាក់រដ្ឋ។ អ្នកវាយតម្លៃ មិនត្រូវបានអនុញ្ញាតឲ្យជួយ ឬបង្រៀនអ្នក ឬពិភាក្សាពីការសម្តែងជាមួយអ្នកទេ។

**នៅពេលតេស្តរបស់អ្នក បញ្ចប់ អ្នកវាយតម្លៃនឹង:**

- បញ្ចូលទិន្នន័យពីការសម្តែងជំនាញរបស់អ្នកចូលទៅក្នុងកុំព្យូទ័រ ដែលនឹងផ្តល់ពិន្ទុតេស្ត។
- ប្រគល់របាយការណ៍ពិន្ទុដល់អ្នក។

**វិន័យទូទៅផ្សេងទៀតសម្រាប់តេស្តនេះ រួមមាន:**

- ឧបករណ៍ថត ទូរសព្ទដៃ ឧបករណ៍ផេជើ PDA ឬកាមេរ៉ា ត្រូវតែបិទ និងទុកនៅក្នុងពេលធ្វើតេស្តរបស់អ្នក។
- ទ្រព្យសម្បត្តិផ្ទាល់ខ្លួនណាមួយ ដែលនៅជាមួយអ្នក ត្រូវតែទុកនៅក្នុងបន្ទប់ធ្វើតេស្ត ហើយអ្នកនឹងមិនត្រូវបានអនុញ្ញាតឲ្យយកទ្រព្យសម្បត្តិរបស់អ្នកចូល នៅក្នុងពេលធ្វើតេស្តឡើយ។
- នេះគឺជាការធ្វើតេស្តសៀវភៅជិតបំផុត។ អ្នក មិនត្រូវបានអនុញ្ញាតឲ្យប្រើ ឬមើលការកត់ត្រាសៀវភៅ ឬព្រឹត្តិប័ត្រព័ត៌មានបេក្ខជនក្នុងពេលធ្វើតេស្តឡើយ។
- ពុំមានការសម្រាកត្រូវបានផ្តល់ឲ្យក្នុងពេលធ្វើតេស្តឡើយ។
- ប្រសិនបើអ្នកមិនបានចុះឈ្មោះក្នុងការធ្វើតេស្តមិនមែនភាសាអង់គ្លេសទេ អ្នកត្រូវតម្រូវឲ្យនិយាយតែភាសាអង់គ្លេសប៉ុណ្ណោះនៅក្នុងតេស្ត មិនថាអ្នកកំពុងធ្វើតេស្ត ឬដើរតួជាអតិថិជននោះទេ។
- តេស្តរបស់អ្នក នឹងត្រូវបញ្ចប់ ហើយអ្នកនឹងត្រូវបណ្តេញចេញ បើអាកប្បកិរិយារបស់អ្នក មិនគួរសមនិងរំខាន។ អ្នក ក៏នឹងត្រូវបានបណ្តេញចេញដែរ បើសិនជាអ្នកវាយតម្លៃ មានហេតុផលដែលអាចជឿថាអ្នកធ្វើដើម្បីអ្នកដទៃ ឬអ្នកត្រូវបានសង្ស័យថាបន្លំក្នុងការធ្វើតេស្ត។

អ្នកនឹងមានឱកាសសួរសំណួរអំពីសេចក្តីណែនាំទាំងនេះ បន្ទាប់ពីអ្នកវាយតម្លៃផ្តល់ឲ្យអ្នកនូវការណែនាំអំពីបន្ទប់ធ្វើតេស្ត។


Copyright © 2010 Prometric Inc., a Delaware corporation. All rights reserved.